| កិច្ចតែងការ | |
|---|---|
| **មុខវិជ្ជា** | វិទ្យាសាស្ត្រ/ចិត្តចលភាព |
| **ប្រធានបទ** | បំណិនអនាម័យ៖<br>-ទម្លាប់រស់នៅមានអនាម័យក្នុងគ្រួសារ និង សង្គម។ |
| **ចំណងជើងមេរៀន** | ល្បែងប៉ោងប៉ោង |
| **កម្រិត** | មធ្យម ៣០ នាទី |
| **គោលបំណង** | -កុមារមានទម្លាប់ល្អមុន និងក្រោយពេល ញុំាអាហារ ចូលបង្គន់អនាម័យ សម្អាត់ខ្លួនប្រាណ សម្ភារៈផ្ទាល់ខ្លួន និងសម្ភារៈលេងផ្សេងៗ។ |
| **បំណិនសម្បទា** | -លាងសម្អាត់ដៃតាមពេលវេលាដូចជា មុន និង ក្រោយពេលញុំាអាហារ ក្រោយចេញពីបង្គន់ និង ពេលបានប៉ះពាល់របស់កខ្វក់<br>-ចោលសម្រាមក្នុងធុងសម្រាម |
| **ចរិយាសម្បទា** | -មានទម្លាប់ល្អក្នុងការធ្វើអនាម័យខ្លួនឯងជាប្រចាំ ដោយការហូបស្អាត ផឹកស្អាត និងរស់នៅស្អាត។ |
| **គ្រូបង្រៀន** | បូមប៉ោងប៉ោងឱ្យគ្រប់ចំនួនដែលត្រូវការលេងល្បែងនេះ សម្រាប់តាមក្រុមនីមួយៗ<br>និងបូកចូលបន្ថែមខ្លះសម្រាប់ត្រៀមទុក<br>នៅពេលដែលពួកគេធ្វើឱ្យបែក។<br>គូររូបមេរោគនៅលើប៉ោងប៉ោង |
| **កុមារ** | -អង្គុយឬឈរជាក្រុម និងមានរបៀបនៅពេល លេង។ |

| | |
|---|---|
| **រៀបចំ** | ប៉ោងប៉ោង ខ្មៅដៃ ស្នប់សម្រាប់បូមប៉ោងប៉ោង ឬប្រើមាត់ក៏បានដែរ |

| **សកម្មភាពគ្រូបង្រៀន** | **មាតិកា** | **សកម្មភាពសិស្ស** |
|---|---|---|
| 1. និយាយជាមួយក្មេងៗអំពីការរីករាលដាលរបស់មេរោគ។ វានឹងមានការរីករាលដាលដោយសារតែអ្នកទាំងអស់គ្នាមិនបានលាងសម្អាតដៃឱ្យបានស្អាតក្រោយពីបានប៉ះពាល់របស់របរផ្សេងៗ។<br>2. បង្ហាញប៉ោងប៉ោងទៅកាន់ក្មេងទាំងអស់ថាប៉ោងប៉ោងទាំងអស់គឺជាមេរោគ។<br>3. បង្ហាញនិងពន្យល់ពីរបៀបនិងច្បាប់នៃការលេងល្បែងហ្នឹង។<br>4. បែងចែកក្មេងៗទៅតាមក្រុមនីមួយៗ និងប្រាប់ពួកគេថាតើ ពួកគេត្រូវលេងល្បែងនៅកន្លែងណា។<br>5. ចែកប៉ោងប៉ោងទៅកាន់ក្មេងៗទាំងអស់ ទៅតាមក្រុមនីមួយៗ<br>6. ប្រសិនបើប៉ោងប៉ោងបែកត្រូវចែកឱ្យពួកគេបន្ថែមទៀតបាន។ | 1. ចំនុចសំខាន់នៅក្នុងការលេងល្បែងមួយនេះគឺមិនឱ្យប៉ោងប៉ោងឬក៏មេរោគណាមួយធ្លាក់ដល់ដីទេ។<br>2. ក្មេងម្នាក់ក្នុងក្រុមនីមួយៗត្រូវបោះប៉ោងប៉ោងទៅលើបន្ទាប់មកក្មេងទាំងអស់នៅតាមក្រុមនីមួយៗត្រូវធ្វើយ៉ាងណាកុំឱ្យវាធ្លាក់មកដល់ដីឱ្យសោះដូចជាទះឬប្រើដៃវាយវាថ្នមៗឱ្យវាឡើងទៅលើវិញ។<br>3. ប្រសិនក្រុមណាធ្វើឱ្យប៉ោងប៉ោងធ្លាក់ដល់ដីនោះពួកគេទាំងអស់ត្រូវសម្តែងធ្វើជាលាងសម្អាតដៃដើម្បីជម្រះមេរោគចេញ។ | 1. ស្តាប់គ្រូនិងឆ្លើយសំណួរ ។<br>2. ស្តាប់ការពន្យល់ពីច្បាប់និងរបៀបលេងល្បែងហ្នឹងដោយយកចិត្តទុកដាក់។<br>3. ប្រសិនបើអ្នកមានប៉ោងប៉ោងអ្នកត្រូវធ្វើយ៉ាងមិចឱ្យវាឡើងទៅលើវិញ តាមដែលអាចធ្វើបាន ។<br>4. នៅពេលដែលព្យាយាមរក្សាវាឱ្យនៅលើមេឃនោះ កុំព្យាយាមរុញឬច្រានគ្នាឱ្យសោះ។ ជៀសវាងកុំឱ្យមានគ្រោះថ្នាក់។<br>5. ប្រសិនបើមានប៉ោងប៉ោងណាដែលធ្លាក់ចុះមកក្រោមក្រុមនោះត្រូវសម្តែងធ្វើជាលាងដៃ |

| | | |
|---|---|---|
| | | ដើម្បីសម្អាតមេរោគចេញជាការស្រេច។ |